ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១០

## ជប៉ុនផ្តល់៣៥៦.៩២៣ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន

រដ្ឋាភិបាលជប៉ុនផ្តល់ជំនួយ តាមរយៈគ្រោងការណ៍សហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូច/សន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) ដែលផ្តល់ទឹកប្រាក់សរុបចំនួន៣៥៦.៩២៣ដុល្លារអាមេរិក ដល់អង្គការទទួលជំនួយចំនួនបួន។ គម្រោងទាំងនេះ គឺគម្រោងចំនួន៣សម្រាប់ប្រព័ន្ធស្រោចស្រព និង មួយទៀតសម្រាប់គម្រោងផ្នែកសុខាភិបាល។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តម ម៉ាសាហ៊ីរ៉ូ គូរ៉ូគី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងអង្គការទទួលជំនួយដើម្បីអនុវត្តគម្រោងដូចខាងក្រោម:



**Photo: Signing ceremony of the four KUSANONE Grant projects held on January 28th.**

## ១. គម្រោងលើកកម្ពស់ការឈានចូលទីផ្សារផលិតផលកសិកម្ម នៅខេត្តពោធិ៍សាត់ (US$95,761)

**អង្គការទទួលជំនួយ: មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តពោធិ៍សាត់**

គម្រោងនេះគឺដើម្បីជួលជុលទំនប់ប្រវែង៣០០០ម៉ែត្រ សាងសង់លូចំនួន៣កន្លែង និង សង់រោងម៉ាស៊ីនកិនស្រូវ និងបំពាក់ម៉ាស៊ីនកិនស្រូវ។ មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តពោធិ៍សាត់ ជាអ្នកអនុវត្តគម្រោង ហើយនឹងប្រគល់ជាបន្តបន្ទាប់សំណង់ធារាសាស្ត្រ និង ម៉ាស៊ីនកិនស្រូវជូនដល់សហគមន៍ដើម្បីធ្វើការថែរក្សា។ ជាមួយនឹងគម្រោងនេះ មានប្រជាកសិករប្រមាណជា ២០០០នាក់ នឹងអាចទទួលបានទឹកស្រោចស្រព និងម៉ាស៊ីន-កិនស្រូវ ព្រមទាំងការបញ្ជូនផលិតផលកសិកម្មទៅកាន់ទីផ្សារបានល្អប្រសើរឡើង ដែលយើងរំពឹងថានឹងធ្វើឱ្យទីផ្សារសេដ្ឋកិច្ចល្អគួរសមឡើងវិញនៅក្នុងតំបន់។

## ២. គម្រោងស្តារប្រព័ន្ធស្រោចស្រពបឹងវាំង នៅខេត្តកំពង់ចាម (US$96,419)

**អង្គការទទួលជំនួយ: មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តកំពង់ចាម**

ដូចគម្រោងខាងលើដែរ ជាមួយនឹងជំនួយនេះ ប្រព័ន្ធស្រោចស្រពបឹងវាំង នឹងត្រូវធ្វើការជួសជុលឡើងវិញ ដោយមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តកំពង់ចាម។ គម្រោងនេះ រួមបញ្ចូលជាមួយការសាងសង់ទ្វារទឹក និង ទំនប់ប្រវែង១៩៦៦ម៉ែត្រឡើងវិញ។ យើងរំពឹងថា គម្រោងនេះនឹងជួយកាត់បន្ថយទឹកជំនន់ដែលធ្វើឱ្យខូចខាតជារៀងរាល់ឆ្នាំ ហើយផ្តល់ភាពងាយស្រួលដល់ការបង្ហូរទឹកចូលស្រែសម្រាប់ប្រជាជនប្រមាណជា១០០០០នាក់ នៅក្នុងតំបន់។ ជាមួយនឹងជំនួយបច្ចេកទេសពីមន្ទីរធនធានទឹក និង ឧតុនិយមខេត្ត សហគមន៍នឹងថែរក្សាប្រព័ន្ធស្រោចស្រពនេះឱ្យមានលក្ខណៈល្អប្រសើរ។

## ៣. គម្រោងស្តារប្រព័ន្ធស្រោចស្រពពោធិ៍តាវ៉ា នៅខេត្តតាកែវ (US$90,348)

**អង្គការទទួលជំនួយ: មន្ទីរធនធានទឹក និង ឧតុនិយម ខេត្តតាកែវ**

ដូចគម្រោងខាងលើផងដែរ ជំប៉ុននឹងជួយមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តតាកែវ ដើម្បីជួសជុលប្រព័ន្ធស្រោចស្រពពោធិ៍តាវ៉ា។ មន្ទីរនឹងលើកទំនប់ប្រវែង៨៥០ម៉ែត្រ សាងសង់សំណង់បង្ហៀរមួយកន្លែង និង លូដោះទឹកមួយកន្លែង ដែលមានប្រជាកសិករប្រមាណជាង១០០០នាក់នៅក្នុងតំបន់ជុំវិញនេះ នឹងអាចគ្រប់គ្រង និងចែកចាយប្រភពទឹក ពីអាងស្តុកបានពេញមួយឆ្នាំ។ សមាជិកនៃគណៈកម្មាធិការអ្នកប្រើប្រាស់ទឹកនឹងថែរក្សា និងប្រើប្រាស់ប្រព័ន្ធ ស្រោចស្រពនេះ ក្រោមការត្រួតពិនិត្យបច្ចេកទេសពីមន្ទីរធនធានទឹក និង ឧតុនិមយខេត្ត។

## ៤. គម្រោងបំពាក់បរិក្ខារពេទ្យមន្ទីរពេទ្យបង្អែកព្រៃកប្បាស នៅខេត្តតាកែវ (US$74,395 )

**អង្គការទទួលជំនួយ: ការិយាល័យស្រុកប្រតិបត្តិ ព្រៃកប្បាស**

ដើម្បីឆ្លើយតបទៅនឹងកង្វះខាតបរិក្ខាពេទ្យសម្រាប់ព្យាបាលអ្នកជម្ងឺ ការិយាល័យស្រុកប្រតិបត្តិ ព្រៃកប្បាស នឹងជួយបំពាក់ ម៉ាស៊ីនវិទ្យុសាស្ត្រ ម៉ាស៊ីនអេកូសាស្ត្រ ម៉ាស៊ីនវាស់បេះដូង និង ម៉ាស៊ីនភ្លើងសម្រាប់ការធ្វើរោគវិនិច្ឆ័យបឋមនៅក្នុងមន្ទីរពេទ្យបង្អែកព្រៃកប្បាស។ គម្រោងនេះអាចធ្វើឱ្យប្រជាជនប្រមាណជាង១៥៥.០០០នាក់ ទទួលសេវាសុខភាពសាធារណៈបានល្អប្រសើរឡើង។

*ជំនួយគំរោង* ***គូសាណូណូ*** *របស់ជប៉ុន* បានចាប់ផ្ដើមឡើងនៅប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩១ ដើម្បីជួយឧបត្ថម្ភដល់កិច្ចប្រឹងប្រែងអភិវឌ្ឍន៍ និង ស្ដាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន ។ ជំនួយនេះមានគោលដៅគាំពារជនដែលងាយរងគ្រោះពីកត្តាផ្សេងៗដូចជា ភាពក្រីក្រភាពអកុសលផ្សេងៗ ដែលគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅការចិញ្ចឹមជីវិត និង សេចក្ដីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្ដល់ទឹកប្រាក់សរុបជាង ៤៣.៨លានដុល្លាអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាលអនុវត្តគម្រោងចំនួន៤៣៥ នៅទូទាំងប្រទេសកម្ពុជា ។

ប្រទេសជប៉ុនបន្តជាអ្នកផ្ដល់ជំនួយច្រើនជាងគេបំផុតដល់ប្រទេសកម្ពុជា ។

---

ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: ០២៣ ២១៧ ១៦១ ទូរសារ: ០២៣ ២១៤ ៣៣០
អ៊ីមែល: keikyou.eojc@online.com.kh
គេហទំព័រ: http://www.kh.emb-japan.go.jp